

# កុមារីអេម៉ា

Nadiah Abidin

Azisa Noor

Let's Read

The Asia Foundation



ខ្ញុំពិតជាចង់ចំណាយពេលវិស្សមកាលរបស់ខ្ញុំនៅឆ្នេរសមុទ្រណាស់ ប៉ុន្តែម៉ាក់ប៉ារបស់ខ្ញុំរវល់ជាមួយការងារថតកុន ហើយទុកខ្ញុំចោល។



ពិតជាគួរឱ្យធុញណាស់!



«សួស្តី រីកា!»
«នរណាគេហ្នឹង?»



រីកាងើបមុខមើល ហើយឃើញក្មេងស្រីម្នាក់។
«សួស្តី!»



នាងប្រាប់ថា នាងឈ្មោះ អេម៉ា!
ហេតុអ្វីបានជានាងស្គាល់ឈ្មោះរីកាដែរ?



តាមពិតទៅឪពុករបស់ពួកគេទាំងពីរគឺជាមិត្តភក្តិនឹងគ្នាទេតើ។
អេម៉ាសួរ៖ «តើឯងចង់លេងទេ?»
តៃរីកា ឆ្ងល់តើគេមានអ្វីលេងជាមួយគ្នាទៅ។



អេម៉ាឱ្យយោបល់៖ «តោះ យើងនាំគ្នាសង់ប្រាសាទខ្សាច់!»។ ស្តាប់ទៅល្អលែងដែរតើ។ វីកាឆ្ងល់តើអេម៉ា នឹងសង់ប្រាសាទខ្សាច់បែបណា...



អេម៉ាមានសម្ភារៈជាច្រើនសម្រាប់លេងដីខ្សាច់!



អស្ចារ្យណាស់!





អេម៉ា ឱ្យយោបល់ទៅហែលទឹកលេងជាមួយគ្នា។
«ខ្ញុំចូលចិត្តហែលទឹក ប៉ុន្តែតើពួកយើងហែលទឹកជាមួយគ្នារបៀបណា...» រីកាឆ្ងល់។



អូ អេម៉ាប្រាប់ថា នាងតែងតែហែលទឹកជាមួយបងប្រុសរបស់
នាងឈ្មោះ ប៉ាទី។
បងប្រុសប៉ាទី នឹងហែលទឹកជាមួយពួកយើង។



អេម៉ា ពិតជាពូកែជ្រមុជទឹកមែន!





ថ្ងៃនេះ រីកា និងអេម៉ាលេងជាមួយគ្នាសប្បាយណាស់!



«ស្អែកពួកយើងលេងជាមួយគ្នាទៀត»។ រីការរៀបរាប់ប្រាប់ឪពុកម្តាយនាងបន្ទាប់ពីលេងយ៉ាងសប្បាយនៅសមុទ្រជាមួយអេម៉ា។

តេត្រា អាម៉ាលា គឺជាជំងឺដ៏កម្រមួយដែលត្រូវបានសម្គាល់ដោយសារអវត្តមាននៃអវយវៈទាំងបួន។ «តេត្រា» មកពីពាក្យក្រិច មានន័យថាបួន ចំណែកឯ«អាម៉ាលា» សំដៅទៅលើកង្វះនៃការលូតលាស់ដៃជើងចាប់តាំងពីកំណើត។ មនុស្សជាច្រើនគិតថាមនុស្សដែលមានជំងឺនេះត្រូវការពឹងផ្អែកជំនួយពីអ្នកដទៃ។ ប៉ុន្តែ តាមការពិត មនុស្សដែលមានជំងឺនេះអាចធ្វើអ្វីជាច្រើនដូចជាអ្នកដទៃដែរ។ពួកគេអាចជិះ និងចុះពីរទេះរុញ បរិភោគអាហារ ស្លៀកពាក់ សរសេរ គូរគំនូរ ហែលទឹក ដើរ និងធ្វើអ្វីផ្សេងៗទៀតដោយខ្លួនឯងបាន។ មនុស្សល្បីឈ្មោះខ្លះដែលមានជំងឺនេះដូចជា ចូអាន អូរីដាន អ្នកនិពន្ធនិងជាសកម្មជនសិទ្ធិជនពិការ ហ្សូលី សាងហ្គុយណូ សិល្បករលំដាប់ពិភពលោកដែលមានបំណងធ្វើជាម្ចាស់មណ្ឌលកុមារកំព្រា នីក វ៉ូជីស៊ីត អ្នកលើកទឹកចិត្តដ៏ល្បីល្បាញម្នាក់ដែលចូលចិត្តហែលទឹក ជិះស្គីលើទឹក និងលោតឆ័ត្រយោង។

©2019, The Asia Foundation

គម្រោងបង្កើតសៀវភៅនេះមានក្មេងស្រី និងស្ត្រីដែលមានឥទ្ធិពលជាច្រើនជាតួឯកក្នុងរឿង ចូលរួមដោយអ្នកនិពន្ធ អ្នកគំនូរ អ្នកកែអត្ថបទ និងអ្នករចនាទំព័រសុទ្ធតែជាស្ត្រី។ សៀវភៅនេះត្រូវបានបង្កើតឡើងតាមរយៈកម្មវិធីសិក្ខាសាលាបង្កើតសៀវភៅ ប្រព្រឹត្តទៅក្រោមការសហការរបស់មូលនិធិ លីធារ៉ា និងមូលនិធិអាស៊ីជាមួយការឧបត្ថម្ភពីក្រុមហ៊ុន អេស្ទើ លូតដឺ ។ មូលនិធិលីធារ៉ា ជាអ្នករៀបចំសិក្ខាសាលានិងការអភិវឌ្ឍវិជ្ជាជីវៈរួមនឹងការកែសម្រួលអត្ថបទ និងការរចនាសៀវភៅ។

## Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.

booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*Emma*, Author: Nadiah Abidin. Illustrator: Azisa Noor. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/

Contributing translators: Somey Chheang and Prum Kunthearo